D00428 T-S

# សុន្ទរកថា

របស់

# ប្រធានគណៈប្រធានរដ្ឋ
# កម្ពុជាប្រជាធិបតេយ្យ

ក្នុង

## សន្និសីទកំពូលលើកទី ៥ នៃប្រទេស
## មិនចូលបក្សសម្ព័ន្ធ

## ក្រុងកូឡុំបូ-ស្រីលង្កា

១៦-១៩ សីហា ១៩៧៦

# អារម្ភកថា

ពីថ្ងៃ ១៦ ដល់ថ្ងៃ ១៩ សីហា ឆ្នាំ ១៩៧៦ សន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ បានប្រជុំនៅកូឡុំបូ ដោយជោគជ័យ ក្នុងបរិយាកាសជំនឿជឿជាក់ សាមគ្គីមុតមាំ នឹងសុទិដ្ឋិនិយមក្លៀវក្លា ។ គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យយើង បានចូលរួមក្នុងសន្និសីទនេះ ហើយបានរួមចំណែកយ៉ាងសកម្ម ក្នុងការធ្វើឲ្យសន្និសីទកំពូលលើកទី ៥ នេះ ដំណើរបានជោគជ័យ យ៉ាងត្រចះត្រចង់ ។

ក្នុងឱកាសនេះ មិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យយើង បានថ្លែងសុន្ទរកថាមួយយ៉ាងសំខាន់ ដែលធ្វើឲ្យគណៈប្រតិភូទាំងអស់ ក្នុងសន្និសីទចាប់អារម្មណ៍យ៉ាងខ្លាំង ។ សុន្ទរកថានេះ បញ្ជាក់ច្បាស់នូវគោលជំហរជាមូលដ្ឋាន របស់កម្ពុជាប្រជាធិបតេយ្យយើង គឺ :

— គោលជំហរឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួន ដោយខ្លួនឯង ។

— គោលជំហរការពារដាច់ខាតលក្ខការណ៍ដ៏ពិសិដ្ឋ របស់មហាគ្រួសារប្រទេសមិនចូលបក្សសម្ព័ន្ធ គឺលក្ខការណ៍ស្មើភាព គោរពឯករាជ អធិបតេយ្យភាព នឹងបូរណភាពទឹកដីគ្នាទៅវិញទៅមក គោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។

— គោលជំហរសាមគ្គីដាច់ខាត ជាមួយចលនាបដិវត្តប្រជាជនសកលលោក នឹងចលនាតស៊ូរបស់ប្រជាជនតតិយលោក

ជាបងប្អូន ដើម្បីឯករាជភាព សេរីភាព ប្រជាធិបតេយ្យ មិត្តភាព និងវឌ្ឍនភាពសង្គម ។

— គោលជំហរខិតខំធ្វើបដិវត្ត៍ នៅក្នុងប្រទេសខ្លួនឲ្យបានល្អ ខិតខំប្រយុទ្ធស្តារសេដ្ឋកិច្ច និងកសាងប្រទេសខ្លួន ឲ្យបានល្អ ដោយគោលជំហរឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួនក្នុងជំនឿជឿជាក់ថា នេះជាការរួមចំណែកមួយ ដល់ចលនាតស៊ូបដិវត្ត របស់ប្រជាជនសកលលោក ដល់ចលនាតស៊ូរំដោះជាតិ របស់ប្រជាជនតតិយលោក ជាបងប្អូន និងដល់ការលើកស្ទួយ បុព្វហេតុនៃមហាគ្រួសារមិនចូលបក្សសម្ព័ន្ធ របស់យើង ។

គោលជំហរទាំងនេះ សុទ្ធតែជាគោលជំហរដែលប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំដ៏ភ្លឺស្វាង របស់អង្គការបដិវត្តកម្ពុជា បានប្រកាន់យ៉ាងខ្ជាប់ខ្ជួន ហើយបានអនុវត្តយ៉ាងជាក់ស្តែង និងយ៉ាងដាច់ខាត ក្នុងគ្រប់កាលៈទេសៈ ជាបន្តបន្ទាប់ ទោះជាក្នុងសភាពការណ៍ប្រយុទ្ធស្លាប់រស់ តឹងតែង លំបាកវេទនា ក្នុងសង្គ្រាមរំដោះជាតិ រំដោះប្រជាជនជាង ៥ ឆ្នាំ កន្លងមកក្តី ក្នុងសភាពការណ៍ក្រោយមហាជ័យជំនះ ១៧ មេសា ១៩៧៥ ក្តី ។

ដូច្នេះ សុន្ទរកថានេះ ជាឯកសារមួយសំខាន់ សារុបនូវគោលជំហរ យ៉ាងរឹងប៉ឹង និងយ៉ាងខ្ជាប់ខ្ជួន របស់ប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើង ។ យើងសូមផ្សាយសុន្ទរកថានេះទាំងស្រុង ជូនបងប្អូនរួមជាតិយើង និងជូនមិត្តជិតឆ្ងាយរបស់យើង ដូចតទៅ ។

# សុន្ទរកថា

របស់

## ប្រធានគណៈប្រធានរដ្ឋ កម្ពុជាប្រជាធិបតេយ្យ

## ក្នុងសន្និសីទកំពូលលើកទី ៥
## នៃប្រទេសមិនចូលបក្សសម្ព័ន្ធ

## ក្រុងកូឡុំបូ–ស្រីលង្កា

## ( ១៦ - ១៩ សីហា ១៩៧៦ )

លោកស្រីប្រធាន

ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

ជាបឋម គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ សូមសំដែងអំណរសរសើរយ៉ាងកក់ក្តៅ ចំពោះការជ្រើសតាំងលោកស្រីរដ្ឋមន្ត្រីទី ១ សិរិម៉ាវ៉ូ បន់ដារ៉ាណៃកេ ឲ្យធ្វើជាប្រធាននៃសន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធយើង ។ យើងខ្ញុំសូមជូនពរ ជូនលោកស្រីប្រធាន ឲ្យទទួលបានជ័យជំនះ ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ ។ ព្រមជាមួយនេះ

យើងខ្ញុំក៏សូមសំដែងជូនលោកស្រីប្រធាន នឹងតាមរយៈលោកស្រីប្រធាន ជូនចំពោះរដ្ឋាភិបាល នឹងប្រជាជនស្រីលង្កា ជាមិត្តនូវគារវកិច្ចយ៉ាងជ្រាលជ្រៅ របស់ប្រជាជន នឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ យើងខ្ញុំ សូមសំដែងអំណរគុណ ដ៏ក្លៀវក្លា ចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ស្និទ្ធស្នាល នឹងការឧបត្ថម្ភគ្រប់បែបយ៉ាង ដែលប្រជាជន នឹងរដ្ឋាភិបាលស្រីលង្កាផ្តល់ចំពោះគណៈប្រតិភូយើងខ្ញុំ ក្នុងពេលដែលយើងខ្ញុំ ស្នាក់អាស្រ័យនៅក្នុងរដ្ឋធានី កូឡំបូ ដ៏ស្រស់នេះ ។

យើងខ្ញុំ សូមធ្វើគារវកិច្ចយ៉ាងជ្រាលជ្រៅ ចំពោះព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ នឹងប្រមុខរដ្ឋាភិបាលទាំងអស់ ដែលជារដ្ឋបុរសដ៏ឆ្នើម មានឈ្មោះបោះសំឡេង ដោយបានធ្វើសកម្មភាពដ៏ថ្លៃថ្លា ជាបន្តបន្ទាប់ជាច្រើន ដើម្បីពង្រឹងខ្លឹមសារនៃចលនាមិនចូលបក្សសម្ព័ន្ធយើង នឹងដើម្បីលើកស្ទួយតួនាទីរបស់ចលនាមិនចូលបក្សសម្ព័ន្ធយើង ឲយខ្ពស់ត្រដែតត្រដឹមលើឆាកអន្តរជាតិបច្ចុប្បន្ន ។

យើងខ្ញុំ សូមសំដែងអំណរសរសើរ យ៉ាងរីករាយ នឹងកក់ក្តៅបំផុត ចំពោះគណៈប្រតិភូបណ្តាប្រទេស ដែលបានដណ្តើមជ័យជំនះ យ៉ាងត្រចះត្រចង់បំផុត លើចក្រពត្រនិយមអាណានិគមនិយម ហើយដែលពេលនេះ ចូលមករួមក្នុងមហាគ្រួសារ នៃប្រទេសមិនចូលបក្សសម្ព័ន្ធយើង ក្នុងឋានៈជាសមាជិកពេញលក្ខណៈ ។ នេះជាជ័យជំនះដ៏ត្រចះត្រចង់ របស់



មិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋសូព្រសុន្ទរកថា នៅសន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ នៅកូឡំបូ

ចលនាយើង ដែលពិតជាជំរុញឲ្យចលនាយើង មានកំឡាំងកាន់តែខ្លាំងក្លា នឹងឥទ្ធិពលកាន់តែត្រដែតត្រដឹមទ្វេឡើង នៅលើឆាកអន្តរជាតិថែមទៀត ។

យើងខ្ញុំ សូមជូនពរស្វាគមន៍យ៉ាងកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនាបដិវត្តជាភាតរៈ យ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ គណៈប្រតិភូសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវៈ ដឹកនាំដោយឯកឧត្តម ប្រធានាធិបតី **ស្វូផានុវង្ស** ដែលចូលរួមសន្និសីទកំពូល ប្រទេសមិនចូលបក្សសម្ព័ន្ធ ក្រោយពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់បដិសន្ធិយ៉ាងត្រចះត្រចង់មក ។

យើងខ្ញុំ សូមសំដែងពរស្វាគមន៍យ៉ាងកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនាបដិវត្តយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះគណៈប្រតិភូសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីទី១ **ផាំ វ៉ាន់ ដុង** ដែលបានមកចូលរួមក្នុងសន្និសីទកំពូល ប្រទេសមិនចូលបក្សសម្ព័ន្ធ បន្ទាប់ពីវៀតណាមបានឯកភាព ក្រោយពីដណ្តើមបានមហាជ័យជំនះ ដ៏ត្រចះត្រចង់មក ។

យើងខ្ញុំ សូមជូនពរស្វាគមន៍យ៉ាងកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនាបដិវត្តជាភាតរៈជ្រាលជ្រៅបំផុត ជូនចំពោះគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីទី១ **ប៉ាក់ សឹង ឆឹល** ។ ការរួមប្រស្រ័យរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ក្នុងមហាគ្រួសារ

មិនចូលបក្សសម្ព័ន្ធយើង ជាការរួមចំណែកពង្រឹង នឹងពង្រីកផ្សារប្រទេសមិនចូលបក្សសម្ព័ន្ធ របស់យើង ។

យើងខ្ញុំ សូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅ ប្រកបដោយមនោសញ្ចេតនាភាតរៈ

— ជូនចំពោះ គណៈប្រតិភូសាធារណរដ្ឋ គីណេប៊ីសៅ ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីទី ១ ហ្វ្រង់ស៊ីស្កូ ម៉ង់ដេស ។

— ជូនចំពោះ គណៈប្រតិភូសាធារណរដ្ឋប្រជាមានិត ម៉ូសំប៊ិច ដឹកនាំដោយឯកឧត្តមប្រធានាធិបតី សាម៉ូរ៉ា ម៉ាសែល ។

— ជូនចំពោះ គណៈប្រតិភូ កាប់វែរ ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីទី ១ ប៉េដ្រូ ពីរ៉េស ។

— ជូនចំពោះ គណៈប្រតិភូ សៅតូម៉េ នឹងព្រីនស៊ីប ដឹកនាំដោយឯកឧត្តម ឡេអូណែល ដាល់វ៉ា ។

— ជូនចំពោះ គណៈប្រតិភូ កូម័រ ដឹកនាំដោយឯកឧត្តមអនុប្រធានាធិបតី មហាម៉ាត់ ហាស្សាណាលី ។

— ជូនចំពោះ គណៈប្រតិភូសាធារណរដ្ឋប្រជាមានិតអង់គោឡា ដឹកនាំដោយឯកឧត្តមប្រធានាធិបតី អាហ្គោស្ទីណូ ណេតូ ។

— ជូនចំពោះ គណៈប្រតិភូ សេសែល ដឹកនាំដោយឯកឧត្តមប្រធានាធិបតី សែម ម៉ង់ឆាំ ។

ដែលទើបផ្តើមបានឯករាជយ៉ាងត្រចះត្រចង់ ហើយដែលបាន ចូលមកពង្រឹង នឹងពង្រីកផ្សារមហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ។



ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល នឹងតំណាងប្រមុខរដ្ឋ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ក្នុងឱកាសថ្ងៃបើកប្រជុំសន្និសីទ នៅក្រុងកូឡុំបូ
( ថ្ងៃ ១៦ សីហា ១៩៧៦ )

គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ដែលមកចូលរួមសន្និសីទកំពូល ប្រទេសមិនចូលបក្សសម្ព័ន្ធ បន្ទាប់ពីមហាជ័យជំនះ ១៧ មេសា ១៩៧៥ នឹងក្រោយការចាត់តាំងអង្គការរដ្ឋថ្មីរបស់ខ្លួន នឹងខិតខំប្រឹងអស់សមត្ថភាព នឹងលទ្ធភាពរបស់ខ្លួន ដើម្បីរួមចំណែកធ្វើយ៉ាងណាឲ្យសន្និសីទកំពូលលើកទី ៥ ដណ្តើមបានជ័យជំនះត្រចះត្រចង់ ។

×

×, ×

លោកស្រីប្រធាន

ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

បីឆ្នាំកន្លងផុតទៅហើយ ក្រោយពីសន្និសីទកំពូលលើកទី៤ នៃប្រទេសមិនចូលបក្សសម្ព័ន្ធយើង នៅអាល់ស៊េរី ។ ក្នុងកំឡុងបីឆ្នាំនេះ មហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង បានពុះពារឧបសគ្គគ្រប់បែបយ៉ាង ដណ្តើមបានជ័យជំនះជាបន្តបន្ទាប់ ទាំងក្នុងការតស៊ូនយោបាយ ទាំងក្នុងការតស៊ូអាវុធ ទាំងក្នុងការតស៊ូសេដ្ឋកិច្ច ទាំងការភ្ញាក់រលឹកកាន់តែច្រើនឡើង ខាងស្មារតីនយោបាយ ទាំងការរីកចំរើន ជាច្រើនខាងការចាត់តាំង ដោយយើងបានពង្រឹង នឹងពង្រីកជួរយើង ជាច្រើនថែមទៀត ។ គឺក្នុងសភាពការណ៍ ដ៏គួរឲ្យរីករាយ ដោយជ័យជំនះជាបន្តបន្ទាប់នេះហើយ ដែលប្រទេសមិនចូលបក្សសម្ព័ន្ធយើង បាន

បើកសន្និសីទកំពូលលើកទី៥ នៅកូឡុំបូ នេះ យ៉ាងឧឡារិក និង យ៉ាងត្រចះត្រចង់ ហើយប្រកបដោយបរិយាកាសជំនឿជឿជាក់ សាមគ្គីភាពមុតមាំ និងសុទិដ្ឋិនិយមក្លៀវក្លា ។

នេះ សបញ្ជាក់ឲយឃើញថាមពល និងទិសវិវត្តទៅមុខ របស់ចលនាយើង ដែលចេះតែរីកចំរើនឡើងជានិច្ច ចាប់តាំងពី បដិសន្ធិមក ។ ពីសន្និសីទកំពូលមួយ ទៅសន្និសីទកំពូលមួយ បែលក្រាដ គែរ លូសាកា អាល់ស៊េ កូឡុំបូ ចំនួនសមាជិក របស់មហាគ្រួសារយើង ចេះតែកើនជាលំដាប់ ។ ចលនាយើង បានពង្រឹង និងពង្រីកជាបន្តបន្ទាប់ ក្នុងការអនុវត្តនូវលក្ខការណ៍ មិនចូលបក្សសម្ព័ន្ធ ។ ទាំងនេះ ធ្វើឲយតួនាទី របស់មហា គ្រួសារមិនចូលបក្សសម្ព័ន្ធយើង កាន់តែមានសារៈសំខាន់ថែម ទៀត ។

ដើមឡើយ ចក្រពត្រនិយម អាណានិគមនិយម ពួក ប្រតិកិរិយា និងពួកប្រទេសអ្នកមានឯទៀត ដែលធ្លាប់តែចាត់ ចែងវាសនាសកលលោក តាមអំពើចិត្តគេ បានវាយដំឡែទាប ចំពោះចលនាយើង ដែលមានតែប្រទេសតូច និងមធ្យម ហើយ នៅក្រមួយចំនួនធ្វើជាសមាជិក ។ ពួកគេវាយប្រហារចលនាយើង ថា យើងមិនអាចមានអនាគតឡើយ ។ ប៉ុន្តែបច្ចុប្បន្ននេះ ពួកគេ លែងធ្វើភ្លៀងធ្វើផ្គរ តាមចិត្តគេចង់បានទៀតហើយ ហើយត្រូវ គិតគូរដល់តួនាទី របស់មហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ។ ប្រទេសតូច នៅក្រ ដែលជាសមាជិកគ្រួសារយើង ដោយសារ កំឡាំងសាមគ្គីភាព បានដណ្តើមឋានៈស្មើមុខស្មើមាត់នឹងគេនៅ



លើឆាកអន្តរជាតិ ពិសេសគឺមិនឲយនរណា មកចាត់ចែងវាសនា របស់យើង ជំនួសយើងតាមអំពើចិត្តគេបានឡើយ ។ សន្និសីទ កំពូលលើកទី៤ របស់យើង នៅអាល់ស៊េ ឆ្នាំ ១៩៧៣ ជាផ្នូរ បត់សំខាន់នៃការវិវត្តរីកចំរើន របស់ចលនាយើង ដោយសន្និសីទ បានលើកកំពស់ការតស៊ូ របស់ប្រទេសនៅក្រ ដ៏កុះករ មិនឲយ ប្រទេសមាន បន្តកេងប្រវ័ញ្ចតទៅទៀត និងបានលើកកំពស់ការ តស៊ូរបស់មហាគ្រួសារយើង ប្រឆាំងអំពើជ្រៀតជ្រែក អំពើវាតទី និងអំពើឈ្លានពាន របស់មហាអំណាចអ្នកមាន ព្រមទាំងបាន អំពាវនាវ ឲយបង្កើតរបបសេដ្ឋកិច្ចអន្តរជាតិថ្មី ។ សន្និសីទរដ្ឋមន្ត្រី ក្រសួងការបរទេស ប្រទេសមិនចូលបក្សសម្ព័ន្ធយើង នៅលីម៉ា ឆ្នាំ ១៩៧៥ ដែលពង្រីក និងពង្រឹងខ្លឹមសារ នៃសន្និសីទកំពូល អាល់ស៊េ បានបញ្ជាំងឲយឃើញថា តួនាទីរបស់ចលនាយើង កាន់តែលេចធ្លោឡើងទៀត ។

ចលនាយើង បានផ្តើបគំនិត ហើយដណ្តើមបានជ័យជំនះ ដ៏ធំធេង នៅមហាសន្និបាតវិសាមញ្ញលើកទី ៦ និងទី ៧ នៃអង្គការ សហប្រជាជាតិ ។ តួនាទីរបស់ចលនាយើង ក៏បានបញ្ជាក់ឡើង ខ្ពស់ត្រដែតទៀត ក្នុងមហាសន្និបាតលើកទី ៣០ នៃអង្គការ សហប្រជាជាតិ និងនៅក្នុងសន្និសីទអន្តរជាតិដទៃទៀត ។

មហាគ្រួសារយើង តែងតែបានសាមគ្គីប្រយុទ្ធយ៉ាងសកម្ម ជាមួយប្រជាជនតតិយលោក សមស្របតាមលក្ខការណ៍មិនចូល បក្សសម្ព័ន្ធ នៃចលនាយើង ។ តាំងពីសន្និសីទកំពូលលើកទី ៤

នៅអាល់សេរិបក ប្រជាជននៅអាស៊ី អាហ្វ្រិក អាមេរិកឡាទីន បានធ្វើការតស៊ូ យ៉ាងអង់អាចក្លាហាន ហើយដណ្តើមបានជ័យជំនះ ដ៏ត្រចះត្រចង់ ធ្វើឲ្យសភាពការណ៍សកលលោកប្រែប្រួលជាខ្លាំង ។ នៅបូព៌ាអាស៊ី ក្រោយពីបានធ្វើសង្គ្រាមប្រកបដោយវីរភាពយ៉ាងខ្ពង់ខ្ពស់ និងដោយគោលជំហរលះបង់ខ្ពស់ ប្រជាជនកម្ពុជាដណ្តើមបានមហាជ័យជំនះជាប្រវត្តិ លើសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក រំដោះកម្ពុជាទាំងស្រុងនិងជាស្ថាពរ ថ្ងៃ ១៧ មេសា ១៩៧៥ ។ វៀតណាមខាងត្បូងក៏ត្រូវបានរំដោះទាំងស្រុង ប្រកបដោយមហាជោគជ័យ ថ្ងៃ ៣០ មេសា ១៩៧៥ ធ្វើឲ្យមានលក្ខណៈសម្បត្តិពេញលេញ ដើម្បីឯកភាពវៀតណាម ។ ប្រជាជនឡាវ ក៏ដណ្តើមបានមហាជ័យជំនះត្រចះត្រចង់ទាំងស្រុងដែរ ។ វីរប្រជាជនសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ទាំងមូល បានវាយបំបាក់ដោយជោគជ័យ ជាបន្តបន្ទាប់ នូវឧបាយកលឈ្លានពានរបស់ចក្រពត្តិអាមេរិក ។ ប្រជាជននៅអាស៊ីអគ្នេយ៍ឯទៀត បាននិងកំពុងតែតស៊ូកាន់តែខ្ពស់ឡើងៗ កំចាត់បក្សសម្ព័ន្ធយោធា និងមូលដ្ឋានយោធាបរទេស ហើយការតស៊ូដើម្បីឯករាជ និងប្រជាធិបតេយ្យ នៅតំបន់នេះ កំពុងវិវត្តល្អណាស់ ។ នៅមជ្ឈិមបូព៌ា ការតស៊ូរបស់ប្រជាជនប៉ាឡេស្ទីន ប្រឆាំងស៊ីយ៉ូនិសនិយម និងវាគទ្ទិនិយមអ៊ីស្រាអែល ឈ្លានពាន បានរីកចំរើនជាលំដាប់ ។ ប្រជាជន និងប្រទេសទាំងអស់ នៃតតិយលោក និងប្រទេស



ស្នេហាសន្តិភាព និងយុត្តិធម៌ទាំងអស់ នៅខាងប្រជាជនប៉ាឡេស្ទីន ជានិច្ច ហើយការតស៊ូដ៏យុត្តិធម៌របស់ប្រជាជនប៉ាឡេស្ទីន ពិតជាឈានទៅកាន់ជ័យជំនះដាច់ខាត ។ ប្រជាជនអារ៉ាប់ដ៏អង់អាចក្លាហាន បានប្រកាន់ខ្ជាប់នូវការតស៊ូដាច់ខាត ប្រឆាំងស៊ីយ៉ូនិសនិយមអ៊ីស្រាអែល និងអំពើជ្រៀតជ្រែកឈ្លានពានគ្រប់បែបយ៉ាង ។ គេទាំងឡាយ ទទួលបានមេរៀន និងបទពិសោធជាច្រើនដ៏ថ្លៃថ្លា ។ គេទាំងឡាយកំពុងឈានទៅកាន់ផ្លូវជ័យជំនះ ហើយប្រាកដជានឹងទទួលបានជ័យជំនះជាប្រាកដ ។ នៅលើទ្វីបអាហ្វ្រិកដ៏រុងរឿង បន្ទាប់ពីការតស៊ូដ៏ស្វិតស្វាញ ប្រកបដោយវីរភាព ប្រឆាំងនឹងអាណានិគមនិយម ប្រជាជនគីណេប៊ីសៅ ម៉ូសំប៊ិច កាប់វែរ សៅតូមេ និងព្រីនស៊ីប កូម័រ អង់គោឡា សេសែល បានសំរេចឯករាជប្រទេសខ្លួន ដោយជោគជ័យជាបន្តបន្ទាប់ តាំងពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៦ នេះ ។ ចលនាសេរីភាពជាតិ របស់ប្រជាជនស៊ីមបាប់វ៉េ ណាមីប៊ី អាសានី ប្រឆាំងអាណានិគមនិយម និងពូជសាសន៍និយមអាហ្វ្រិកខាងត្បូង កំពុងមានសន្ទុះខ្លាំងក្លា ហើយប្រាកដជាដណ្តើមបានជ័យជំនះទីអវសាន ។ ប្រជាជនអាមេរិកឡាទីន ទាំងមូល បានសាមគ្គីគ្នាយ៉ាងជិតស្និទ្ធ សហការគ្នា ហើយបានតស៊ូការពារដោយជោគជ័យនូវអធិបតេយ្យភាព និងសិទ្ធិគ្រប់គ្រងធនធានជាតិរបស់ខ្លួន ។ ប្រទេសតតិយលោក បានសាមគ្គីគ្នា យ៉ាងជិតស្និទ្ធ ដើម្បីតស៊ូបង្កើតឲ្យមានរបបសេដ្ឋកិច្ចអន្តរជាតិថ្មីមួយវិញ ។

ចលនាប្រទេសមិនចូលបក្សសម្ព័ន្ធ របស់យើង បានប្រកាន់តួនាទី ដ៏ត្រឹមត្រូវរបស់យើង ដែលប្រវត្តិសាស្ត្របានប្រគល់ឲ្យ គឺផ្តល់ការឧបត្ថម្ភគាំទ្រ យ៉ាងមោះមុត ដោយឥតលក្ខខណ្ឌ ដោយស្មារតីសាមគ្គីក្លៀវក្លាប្រយុទ្ធ ចំពោះគ្រប់ចលនាតស៊ូរំដោះជាតិ របស់ប្រជាជនតតិយលោក ប្រឆាំងនឹងគ្រប់សកម្មភាពឈ្លានពាន នឹងជ្រៀតជ្រែក ។ ចលនាយើង បានលើកទឹកចិត្តយ៉ាងខ្លាំងក្លា ដល់ប្រជាជនតតិយលោកទាំងមូល ដែលធ្លាប់ត្រូវរងគ្រោះ ដោយអំពើឈ្លានពាន នឹងអំពើជ្រៀតជ្រែក មកពីខាងក្រៅ ហើយដែលកំពុងតស៊ូយ៉ាងអង់អាច ។

ប្រជាជនកម្ពុជាយើងខ្ញុំ ដែលធ្លាប់រងគ្រោះពីសង្គ្រាមឈ្លាន-ពាន របស់ចក្រពត្រអាមេរិក ហើយដែលធ្លាប់បានតស៊ូតឹងតែងលំបាកវេទនា ប្រឆាំងទល់នឹងសង្គ្រាមឈ្លានពាន របស់ចក្រពត្រអាមេរិក នឹងបរិវារ ក៏ដូចប្រជាជាជនតតិយលោកទាំងអស់ ដែលកំពុងតស៊ូ បានស្គាល់យ៉ាងច្បាស់ នូវដំឡៃយ៉ាងថ្លៃថ្លា នូវប្រសិទ្ធិ-ភាពយ៉ាងពិតប្រាកដ នៃការឧបត្ថម្ភ ខាងផ្លូវចិត្ត ខាងផ្លូវស្មារតី ខាងផ្លូវនយោបាយ នឹងខាងផ្លូវទូត របស់មហាគ្រួសារយើង ។ ពិតមែនតែមហាគ្រួសារយើងនៅក្រ ហើយខ្វះខាតសំភារៈ ខ្វះខាតលុយកាក់ ខ្វះខាតអាវុធយុទ្ធភ័ណ្ឌ ដើម្បីជួយដល់ការតស៊ូ របស់ប្រជាជនតតិយលោកជាបងប្អូនក៏ដោយ ប៉ុន្តែការជួយឧបត្ថម្ភគ្នា ខាងគោលជំហរ ខាងស្មារតីសាមគ្គី ខាងការលើកទឹកចិត្តគ្នាទៅវិញទៅមក តាមគោលជំហរការពារសិទ្ធិរបស់



ប្រជាជននៃគ្រប់ប្រទេសនីមួយ ៗ តូចក្តី ធំក្តី កាន់កាប់វាសនាខ្លួន ដោយខ្លួនឯង តាមគោលជំហរការពារអំពើយុត្តិធម៌ ប្រឆាំងនឹងអំពើអយុត្តិធម៌ ជ្រៀតជ្រែកឈ្លានពាន ការជួយឧបត្ថម្ភបែបនេះ ពីមហាគ្រួសារយើង បានលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់ប្រជាជនគ្រប់ប្រទេសដែលតស៊ូ ដើម្បីឯករាជ អធិបតេយ្យភាពរបស់ខ្លួន ហើយបានប្រែក្លាយទៅជាកំឡាំងសំភារៈមួយ ដែលវាយសំពងយ៉ាងខ្លាំងក្លា ទៅលើកំឡាំងឈ្លានពាន ជ្រៀតជ្រែកទាំងអស់ ធ្វើឲ្យវាបរាជ័យជាបន្តបន្ទាប់ ។ តាមរយៈនេះ មហាគ្រួសារយើង បានរួមចំណែកយ៉ាងសកម្ម នឹងយ៉ាងសំខាន់ ក្នុងការសំរេចជ័យជំនះ នៃប្រជាជនកម្ពុជាយើងខ្ញុំ នឹងប្រជាជនតតិយលោកផ្សេង ៗ ទៀត ។

ព្រមជាមួយនេះ ជ័យជំនះដ៏ត្រចះត្រចង់ របស់ប្រជាជនដែលកំពុងតស៊ូ អំណោយផលយ៉ាងខ្លាំងក្លា ដល់បុព្វហេតុដែលមហាគ្រួសារយើង ការពារ នឹងតស៊ូដើម្បីឲ្យសំរេច ។ ជ័យជំនះនេះ ក៏អំណោយផលយ៉ាងខ្លាំងក្លា ដល់កិច្ចការពារឯករាជភាពអធិបតេយ្យភាព នៃប្រទេសយើងនីមួយ ៗ ផងទៀត ។ ហើយជ័យជំនះក៏លើកស្ទួយតួនាទី របស់មហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ឲ្យរឹតតែខ្ពស់ត្រដែតត្រដឹមទៀត ហើយក៏ជាទុនដ៏ធំធានាដល់អនាគតភ្លឺស្វាង របស់ចលនាយើង ។

ដូច្នេះ តាំងពីសន្និសីទកំពូលលើកទី ១ រហូតដល់សន្និសីទកំពូលលើកទី ៥ នេះ ចលនាយើងទទួលបានលទ្ធផលជាជ័យជំនះ

ជាបន្តបន្ទាប់ ។ ឧបសគ្គ នឹងការស្មុគស្មាញក៏មានច្រើន តែនេះជាការធម្មតាទេ របស់ចលនាតស៊ូរបស់យើង ។ ប៉ុន្តែ តាមគោលជំហរសាមគ្គីភាព ស្មើភាព គោរពឯករាជភាព គោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមក ចលនាយើងបានឆ្លងកាត់ឧបសគ្គ ដែលគំរាមកំហែងយើង មកពីខាងក្រៅ ដោយជោគជ័យ ជាបន្តបន្ទាប់ ក៏ដូចជាដោះស្រាយបញ្ហាស្មុគស្មាញផ្សេងៗទៀត បានជាបន្តបន្ទាប់ដែរ ។

ឈរលើពិសោធ ដែលចលនាយើងទទួលបានលទ្ធផលល្អយ៉ាងនេះ យើងរឹតតែមានជំនឿជឿជាក់ថា ទោះជាតទៅមុខទៀត ចលនាយើងត្រូវជួបប្រទះឧបសគ្គថ្មីៗទៀត ដែលជៀសមិនផុតយ៉ាងណាក៏ដោយ ក៏ចលនាយើងនឹងបោះជំហានទៅមុខជានិច្ច ។

លទ្ធផលដ៏ត្រចះត្រចង់ទាំងប៉ុន្មាន ដែលចលនាយើងដណ្តើមបានកន្លងមកនេះ បានមកពីការខំប្រឹងប្រែង របស់សមាជិកនីមួយៗនៃចលនាយើង ដែលប្រកាន់ខ្ជាប់លក្ខការណ៍មិនចូលបក្សសម្ព័ន្ធ នឹងបានមកពីកំឡាំងសាមគ្គីភាព នឹងជួយគ្នាទៅវិញទៅមក ក្នុងមហាគ្រួសារយើង ។ ក្នុងការបូកសរុប សភាពការណ៍នៃចលនាយើង ពីសន្និសីទកំពូលលើកទី ៤ មកលើកទី ៥ នេះ គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ សូមវាយតំលៃយ៉ាងខ្ពស់ចំពោះសមត្ថភាពដ៏ខ្ពង់ខ្ពស់ នឹងសកម្មភាពមហាញ៉ត របស់ឯកឧត្តម ហ៊ួរី ប៊ូមេឌៀន ប្រធានាធិបតីសាធារណរដ្ឋអាល់ហ្សេរី



ប្រជាធិបតេយ្យ នឹងប្រជាមានិត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម របស់ឯកឧត្តម ជាប្រធានសន្និសីទកំពូល ប្រទេសមិនចូលបក្សសម្ព័ន្ធលើកទី ៤ តាំងពី ១៩៧៣ មក ។ យើងខ្ញុំ សូមសំដែងនូវការកោតក្តុយ៉ាងជ្រាលជ្រៅ នឹងអំណរសរសើរ យ៉ាងកក់ក្តៅបំផុត ចំពោះឯកឧត្តម ។

ការតស៊ូប្រកបដោយជ័យជំនះ របស់ប្រជាជននៅអាស៊ី អាហ្វ្រិក អាមេរិកឡាទីន នឹងសាមគ្គីភាពផ្ទៃក្នុងយើង ជាកត្តាអំណោយផលដល់ចលនាមិនចូលបក្សសម្ព័ន្ធយើង ជាការពិតណាស់ ។ ប៉ុន្តែ ចលនាយើងត្រូវប្រឈមមុខតទល់នឹងគ្រោះអាសន្ន ដែលបណ្តាលមកពីមហិច្ឆតា លោភលន់ នឹងរាជាធិរបស់មហាអំណាចអ្នកមាន តទៅទៀត ។ ក្នុងសកម្មភាពដ៏អាក្រក់របស់ពួកគេ ពួកគេតែងតែលូកដៃចូលបំបែកចលនាយើង ហើយតែងតែរិះរកវិធីគ្រប់បែបយ៉ាង ដើម្បីជ្រៀតជ្រែក នឹងឈ្លានពាន សមាជិកគ្រួសារយើងនីមួយៗ ។

ប្រទេសនៅក្នុងចលនាយើងនេះ ជាប្រទេសនៅក្រ ហើយទន់ខ្សោយជាការពិតណាស់ ។ តែយើងចង់កាន់កាប់វាសនារបស់យើង ដោយខ្លួនយើង ។ យើងមិនចង់ឲ្យអ្នកដទៃណាមកជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់យើង មកឈ្លានពានយើង មករំលោភលើអធិបតេយ្យភាពយើង មករំលោភលើបូរណភាពដែនដីរបស់យើង ជាដាច់ខាត ។ ដូច្នេះ សាមគ្គីភាព ដើម្បីរួមកំឡាំងគ្នា ការពារឯករាជភាព អធិបតេយ្យភាព បូរណភាព

ដែនដីរបស់យើង ការពារសិទ្ធិចាត់ចែងវាសនាយើងម្នាក់ ៗ ដោយខ្លួនយើង ដោយឯករាជម្ចាស់ការ ជាការចាំបាច់នឹងពិសិដ្ឋណាស់ ។ គឺសាមគ្គីភាព រឹងប៉ឹង ឈរលើលក្ខការណ៍ដ៏ពិសិដ្ឋ របស់ប្រទេសមិនចូលបក្សសម្ព័ន្ធយើង ពោលគឺលក្ខការណ៍សមភាព គោរពឯករាជភាព អធិបតេយ្យភាព បូរណភាពដែនដីគ្នាទៅវិញទៅមក ជួយឧបត្ថម្ភគ្នាទៅវិញទៅមក មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នា គោរពសិទ្ធិរបស់ប្រជាជនប្រទេសនីមួយៗ ចាត់ចែងកិច្ចការខ្លួន ដោយខ្លួនឯង ដោយឯករាជ ម្ចាស់ការ ។

ខ្លឹមសារនៃលក្ខការណ៍មិនចូលបក្សសម្ព័ន្ធយើង ជាឆន្ទៈដ៏មោះមុត នឹងជាសំណូមពរដ៏ជ្រាលជ្រៅ របស់ប្រជាជនតតិយលោក រាប់ពាន់លាននាក់ ដែលភ្ញាក់រលឹកនយោបាយខ្ពស់ ហើយកំពុងខិតខំកាន់កាប់វាសនាខ្លួន នឹងប្រទេសជាតិខ្លួន ដោយខ្លួនឯង ។ ដូច្នេះ ជាកំឡាំងមហិមាអស្ចារ្យណាស់ គ្មានកំឡាំងណាអាចរារាំងបានឡើយ ។ លក្ខការណ៍ដ៏ពិសិដ្ឋ របស់ប្រទេសមិនចូលបក្សសម្ព័ន្ធយើង វាធានាអះអាងណាស់ ក្នុងការពង្រឹងនឹងពង្រីកសាមគ្គីភាព នៃជួរប្រទេសមិនចូលបក្សសម្ព័ន្ធយើង វាធានាអះអាងណាស់ ដល់ការដណ្តើមជ័យជំនះរំដោះជាតិយើងនឹងប្រជាជនយើង ហើយវាធានាអះអាងណាស់ ដល់ការវាយកំចាយនូវគ្រប់ឧបាយកលជ្រៀតជ្រែក នឹងឈ្លានពានមកលើឯករាជភាព អធិបតេយ្យភាព នឹងបូរណភាពដែនដីរបស់យើង ។




ក្នុងឋានៈជាអនុប្រធាន នៃសន្និសីទកំពូលលើកទី ៥ មិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ ធ្វើជាអធិបតីអង្គប្រជុំ សន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធ នៅក្រុងកូឡុំបូ

12

កម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ សូមប្រកាសជាឧឡារិក នៅទីនេះម្តងទៀតថា ខ្លួនប្រកាន់ខ្ជាប់នឹងដាច់ខាត នូវបេក្ខ-ការណ៍ដ៏ពិសិដ្ឋ របស់ប្រទេសមិនចូលបក្សសម្ព័ន្ធយើង នៅគ្រប់កាលៈទេសៈ ។

× 

× ×

លោកស្រីប្រធាន
ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

កម្ពុជា ជាប្រទេសមិនចូលបក្សសម្ព័ន្ធ តាំងពីដើមរៀងរហូតមក ។ ប្រជាជនកម្ពុជាតែងតែមានជំនឿលើខ្លឹមសារនៃបេក្ខ-ការណ៍មិនចូលបក្សសម្ព័ន្ធ ។ សំណូមពរជាមូលដ្ឋាន និងជាពិសិដ្ឋ របស់ប្រជាជនកម្ពុជាយើងខ្ញុំ គឺចង់បានរដ្ឋកម្ពុជាមួយ ឯករាជ ឯកភាព អធិបតេយ្យភាព សន្តិភាព អព្យាក្រិត ប្រជា-ធិបតេយ្យ ក្នុងបូរណភាពដែនដីរបស់ខ្លួន មិនចូលបក្សសម្ព័ន្ធ ។

តែចក្រពត្តិអាមេរិក នឹងបរិវារគ្រប់ប្រភេទ តាំងពីឆ្នាំ ១៩៥៥ មក វារុករួន ធ្វើវិទ្ធង្សនា អន្តរាគមន៍ ប្រឆាំងប្រជាជាតិ ប្រជាជនកម្ពុជា យើងខ្ញុំ ។ ក្នុងពេលនោះ ប្រជាជន

នឹងអ្នកស្នេហាជាតិយើងខ្ញុំ បានបាត់បង់ជីវិតជាច្រើន ។ ប៉ុន្តែ ដោយមានឆន្ទៈមោះមុត ប្រកាន់ខ្ជាប់នូវសំណូមពរជាមូលដ្ឋាន នឹងដ៏ពិសិដ្ឋរបស់ខ្លួន ប្រជាជាតិ នឹងប្រជាជនកម្ពុជាយើងខ្ញុំ បាន ធ្វើការតស៊ូយ៉ាងអង់អាច តាមរូបភាពនយោបាយផង នឹងអាវុធ ផង ផណ្ដើមបានជ័យជំនះជាបន្តបន្ទាប់ ហើយរក្សា នឹងការពារ កម្ពុជាឯករាជ អព្យាក្រឹត នឹងមិនចូលបក្សសម្ព័ន្ធបាន ពិសេសតស៊ូ ប្រឆាំងដាច់ខាត វាយកំចាយមិនឲ្យមានមូលដ្ឋានឈ្លានពាន របស់ចក្រពត្រអាមេរិក នៅលើដែនដីខ្លួនបាន រហូតមកដល់ ឆ្នាំ ១៩៧០ ។

ចំពោះមុខ នៃការបរាជ័យដ៏ធ្ងន់របស់វា ជាបន្តបន្ទាប់ បក ចក្រពត្រអាមេរិក នឹងពួកអាក្បត់ លន់ណុល បានធ្វើ រដ្ឋប្រហារ មហាក្បត់ជាតិ មហាប្រតិកិរិយា ថ្ងៃ ១៨ មីនា ១៩៧០ ហើយធ្វើសង្គ្រាមមហាវិនាសកម្ម ដ៏ធំសំបើមអស្ចារ្យ ពិនដែលមានទេ ក្នុងប្រវត្តិសាស្ត្រកម្ពុជាយើងខ្ញុំ ដើម្បីបំផ្លាញ ឯករាជ អព្យាក្រឹត សន្តិភាពរបស់កម្ពុជាយើងខ្ញុំ នឹងយកកម្ពុជា យើងខ្ញុំ ធ្វើជាមូលដ្ឋានសឹករបស់វា នឹងធ្វើជាអាណានិគមថ្មីរបស់ វា ។ ដើម្បីឈ្លានពានប្រទេសមួយដ៏តូច ចក្រពត្រអាមេរិក ដែលជាមហាអំណាចចក្រពត្រធំជាងគេបំផុត ឃោរឃៅព្រៃ-ផ្សៃជាងគេបំផុត លើសកលលោក បានប្រើគ្រប់មធ្យោបាយ សង្គ្រាម ប្រើអាវុធយុទ្ធភ័ណ្ឌទំនើបគ្រប់ពុន លើកលែងតែ គ្រាប់បែកបរមាណូ មួយមុខចេញ ហើយបានប្រើគ្រប់រូបភាព



សង្គ្រាមឈ្លានពាន មានតាំងពីប្រើកងទ័ពជើងគោកអាមេរិក ឲ្យមកឈ្លានពានផ្ទាល់ ប្រើកងទ័ពអាយ៉ង ធីវ គី ប្រើកងទ័ព ពួកអាក្បត់លន់ណុល ជាឧបករណ៍ឈ្លានពាន រហូតដល់ប្រមូល យន្តហោះគ្រប់ពុនរបស់វា ពិសេស បេ៥២ នៅអាស៊ី នឹងនៅ តំបន់ប៉ាស៊ីហ្វិកមកអនុវត្ត «អាមេរិកូបនីយកម្មសង្គ្រាមអាកាស» នៅកម្ពុជា ។

ក៏ប៉ុន្តែ ប្រជាជនកម្ពុជា នៅឈរជ្រងោរងោ យ៉ាងអង់ អាចក្លាហានតស៊ូតតាំងនឹងសង្គ្រាមឈ្លានពាន ដ៏សែនឃោរឃៅ ព្រៃផ្សៃ របស់ចក្រពត្រអាមេរិក នឹងបរិវារវានេះ ។ ដោយ មានការឧបត្ថម្ភគាំទ្រ ពីសំណាក់មិត្តជិតឆ្ងាយ ក្នុងសកលលោក ពិសេសពីប្រទេសមិនចូលបក្សសម្ព័ន្ធផង ប្រជាជនយើងខ្ញុំ ប្រកាន់ ខ្ជាប់ គោលជំហរឯករាជ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់ វាសនាខ្លួន នឹងប្រទេសជាតិខ្លួន ដោយខ្លួនឯង ។ ប្រជាជន នឹង កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំ ហ៊ាន នឹងបានធ្វើពលីកម្មដ៏សែនធំធេង ទ្រាំទ្រលំបាកវេទនាពុះពារឧបសគ្គគ្រប់បែបយ៉ាង ប្រយុទ្ធពឹងតែង ស្វិតស្វាញគ្រប់ពេលវេលា ធ្វើសង្គ្រាមបដិវត្តរំដោះជាតិ រំដោះ ប្រជាជន ទាំងនៅសមរភូមិមុខ ទាំងនៅសមរភូមិក្រោយ យ៉ាង សស្រាក់សស្រាំ គគ្រឹកគគ្រេង ។ ដោយសឹងតែមាន តែបាត ដៃទទេ ប្រជាជន នឹងកងទ័ពបដិវត្តកម្ពុជាយើងខ្ញុំ ខិតខំកសាង កំឡាំងខ្លួនលើគ្រប់ផ្នែក ដោយផ្អែកលើកំឡាំងខ្លួនផ្ទាល់ផ្គត់ផ្គង់ស្បៀង នឹងសំលៀកបំពាក់ ខិតខំច្នៃប្រឌិតធ្វើអាវុធយុទ្ធភ័ណ្ឌ នឹងវាយ

ដណ្តើមអាវុធពីខ្មាំងទៅវាយខ្មាំងវិញ ។ ប្រជាជន និងកងទ័ពបដិវត្តកម្ពុជាយើងខ្ញុំ បានវាយសំរុកផាប់ វាយសំរុកអស់រយៈ ៥ ឆ្នាំ មួយខែ រហូតដល់ចក្រពត្រអាមេរិក និងបរិវារវា ត្រូវបរាជ័យទាំងស្រុង និងជាស្ថាពរ ។

ថ្ងៃ ១ មេសា ១៩៧៥ ជាថ្ងៃដែលកំណត់នូវបរាជ័យទាំងស្រុង និងជាស្ថាពរនូវនយោបាយខ្មែរូបនីយកម្មសង្គ្រាម របស់ចក្រពត្រអាមេរិកនៅកម្ពុជា ជាថ្ងៃដែលកំណត់នូវបរាជ័យទាំងស្រុង និងជាស្ថាពរ នៃត្រឹកស្តី និចសុន ដែលយកខ្មែរក្បត់ វាយប្រជាជនកម្ពុជា ។ គឺជាថ្ងៃ ដែលពួកអាក្បត់ លន់ណុល ដែលជាព្រលឹងនៃនយោបាយ ខ្មែរូបនីយកម្មសង្គ្រាម របស់ចក្រពត្រអាមេរិក ត្រូវរត់ចេញពីកម្ពុជា យ៉ាងកំសាកបំផុត ។

ថ្ងៃ ១២ មេសា ១៩៧៥ គឺជាថ្ងៃ ដែលឯកអគ្គរដ្ឋទូតអាមេរិក និងអគ្គបញ្ជាការយោធាអាមេរិកទាំងអស់ ដាក់មេដាយរត់ចេញពីភ្នំពេញ តាមឧទ្ធម្ភាគចក្រ ដើម្បីគេចខ្លួនផុត ពីការផ្តន្ទាទោសរបស់ប្រជាជន និងកងទ័ពបដិវត្តកម្ពុជា យើងខ្ញុំ ។

ថ្ងៃ ១៧ មេសា ១៩៧៥ យើងខ្ញុំរំដោះភ្នំពេញ ទាំងស្រុង និងកម្ពុជាទាំងមូល ជាថ្ងៃបញ្ចប់នូវសង្គ្រាមឈ្លានពាន ដ៏សែនខ្លោចផ្សា ដ៏សែនឃោរឃៅព្រៃផ្សៃ និងមហាវិនាសកម្មរបស់ចក្រពត្រអាមេរិក មកលើប្រជាជាតិ និងប្រជាជនកម្ពុជាយើងខ្ញុំ ។

មហាជ័យជំនះនេះ ដែលប្រជាជនកម្ពុជាយើងខ្ញុំដណ្តើមបាន បានមកពីអង្គការបដិវត្តយើងខ្ញុំដឹកនាំ មានមាគ៌ាត្រឹមត្រូវ



ពិសេសមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួន ដោយខ្លួនឯងជាមូលដ្ឋាន បានមកពីវីរភាពបដិវត្តដ៏ខ្ពង់ខ្ពស់ និងពលើកម្លាំងដ៏ធំធេង របស់ប្រជាជន និងកងទ័ពបដិវត្តកម្ពុជាយើងខ្ញុំ ។

កត្តាប្រជាជនកម្ពុជា ទិតទំប្រយុទ្ធដោយខ្លួនឯង ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់អង្គការបដិវត្តខ្លួន ជាកត្តាកំណត់ជាមូលដ្ឋាននៃជ័យជំនះ ក៏ពិតមែន ។ ប៉ុន្តែ ជ័យជំនះរបស់យើងខ្ញុំ ក៏បានមកពីការឧបត្ថម្ភគាំទ្រ គ្រប់បែបយ៉ាង លើឆាកអន្តរជាតិ ដែលប្រជាជាតិ និងប្រជាជនកម្ពុជាយើងខ្ញុំ ទទួលពីសំណាក់គ្រួសារនៃប្រទេសមិនចូលបក្សសម្ព័ន្ធយើង ពីសំណាក់នៃមិត្តជិតឆ្ងាយទាំងអស់ លើទ្វីបទាំង ៥ ព្រមទាំងពីសំណាក់ប្រជាជន និងប្រទេសស្នេហាសន្តិភាពនិងយុត្តិធម៌ នៅលើសកលលោក ក្នុងនោះមានទាំងប្រជាជន យុវជន និងអ្នកនយោបាយស្នេហាសន្តិភាព និងចំរើនអាមេរិកផង ។ សន្និសីទកំពូលលើកទី ៤ នៅអាល់ហ្សេ ឆ្នាំ ១៩៧៣ បានសំដែងសាមគ្គីភាពយ៉ាងមោះមុត ចំពោះបុព្វហេតុរំដោះជាតិ របស់ប្រជាជនកម្ពុជាយើងខ្ញុំ ។ ការឧបត្ថម្ភគាំទ្រសមានចិត្ត និងការលើកទឹកចិត្ត របស់មហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ដល់ការតស៊ូរបស់ប្រជាជនកម្ពុជាយើងខ្ញុំ ធ្វើឲ្យប្រជាជនកម្ពុជាយើងខ្ញុំ មានជំនឿជឿជាក់រឹតតែខ្លាំងឡើងទៀតលើចលនាប្រទេសមិនចូលបក្សសម្ព័ន្ធយើង ។ ទៀតទាំងកាលដ៏មហោឡារិក នៃសន្និសីទកំពូលលើកទី ៥ នៃមហាគ្រួសារយើង

15

នេះ យើងខ្ញុំសូមសំដែងសាជាថ្មី នូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តមប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងប្រទេសជាមិត្តជិតឆ្ងាយទាំងអស់ ដែលបានធ្វើសកម្មភាពថ្លៃថ្លា ឧបត្ថម្ភដល់បុព្វហេតុរំដោះជាតិ របស់ប្រជាជនកម្ពុជាយើងខ្ញុំ ។ យើងខ្ញុំដឹកល់គុណូបការៈ របស់មិត្តជិតឆ្ងាយទាំងអស់ ជារៀងរហូត ហើយប្តេជ្ញារួមសាមគ្គីជួយគ្នាទៅវិញទៅមក ជាមួយមិត្តជិតឆ្ងាយទាំងអស់ លើសកលលោក ពិសេសជាមួយមហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ជារៀងរហូតទៅ ។

ក្រោយរំដោះបក ប្រជាជន និងរដ្ឋាភិបាលយើងខ្ញុំ ត្រូវប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរជាច្រើន បណ្តាលពីសង្គ្រាមឈ្លានពាន ដ៏សែនព្រៃផ្សៃយង់ឃ្នង របស់ចក្រពត្តិអាមេរិក ។ កំឡាំងប្រជាជន ត្រូវអន្តរាយ ជាងមួយលាននាក់ក្នុងប្រជាជនជាង ៨ លាននាក់ ។ កំឡាំងខាងពលកម្ម ជាសត្វពាហនៈ រាប់សែនក្បាល ត្រូវវិនាសអន្តរាយខ្ទេចខ្ទី ។ រោងចក្រ ស្រែចំការ ភូមិករ ជាច្រើនត្រូវអន្តរាយ ។ ផ្លូវគមនាគមន៍ទាំងអស់ ខ្លះត្រូវអន្តរាយទាំងស្រុង ខ្លះទៀតត្រូវអន្តរាយពី ៧០ ទៅ ៨០ ភាគរយ ។ បញ្ហាស្បៀង ចោទជាខ្លាំង ។ ថែមពីលើនេះ ខ្មាំងវានៅតាមបំផ្លាញលទ្ធផលនៃជ័យជំនះ របស់ប្រជាជនកម្ពុជាយើងខ្ញុំទៀត ដូចមានរឿងកប៉ាល់ « ប៉ាយ៉ាហ្គេស » ខែឧសភា ១៩៧៥ និងរឿងទំលាក់គ្រាប់បែកលើក្រុងសៀមរាប ខែកុម្ភៈ ១៩៧៦ ជាដើម ។ ទោះបីយ៉ាងនេះក៏ដោយ យើងខ្ញុំបានពុះពារឧបសគ្គ



គ្រប់បែបយ៉ាង បង្កបង្កើនផលសស្រាក់សស្រាំ ដោយឈរលើជំហរ ខ្លួនទីពឹងខ្លួន ជាសំខាន់ ដោះស្រាយជីវភាពប្រជាជនកម្ពុជាយើងខ្ញុំបានជាមូលដ្ឋាន តាំងពីក្រោយរំដោះបក ពិសេសខាងស្បៀងអាហារ ហើយបច្ចុប្បន្ននេះ សភាពការណ៍ ជីវភាពប្រជាជន កំពុងវិវត្តមកកាន់តែល្អ ជាបណ្តើរៗទៀត ។ យើងខ្ញុំខិតខំបន្តដោះស្រាយតទៅទៀត ដោយឈរលើគោលជំហរ ឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដាច់ខាត និងដោយឈរលើកំឡាំងសាមគ្គីជាតិទាំងមូលតទៅទៀត ហើយនឹងដោយការជួយឧបត្ថម្ភគាំទ្រ ពីសំណាក់មិត្តជិតឆ្ងាយក្នុងសកលលោកផង ។ យើងខ្ញុំ ដឹងច្បាស់ យល់ច្បាស់ និងមានពិសោធច្បាស់ តាមការតស៊ូបដិវត្តដ៏យូរលង់របស់ខ្លួនថា ដើម្បីដណ្តើមឯករាជនយោបាយ ឱ្យបានបរិសុទ្ធ យើងខ្ញុំត្រូវតស៊ូឈរលើជំហរឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ជាកត្តាកំណត់មូលដ្ឋាន ។ តាមពិសោធនេះ ដើម្បីយើងខ្ញុំដណ្តើមបានឯករាជសេដ្ឋកិច្ច ឱ្យបានបរិសុទ្ធ យើងខ្ញុំត្រូវខំប្រឹង ដោយឈរលើជំហរ ឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួន តទៅទៀត ហើយទាល់តែសេដ្ឋកិច្ចយើងខ្ញុំមានឯករាជបរិសុទ្ធ ទើបធានាដល់ឯករាជនយោបាយរបស់យើងខ្ញុំ ឱ្យរក្សាភាពបរិសុទ្ធបាន ។

រីឯសន្តិសុខ លើផ្ទៃប្រទេសយើងខ្ញុំទាំងមូល ក៏មានសភាពនឹងន ស្ងប់ស្ងាត់ល្អ ធានាពេញលេញឱ្យប្រជាជនយើងខ្ញុំបាន

លក្ខណៈសម្បត្តិល្អប្រសើរ ដើម្បីស្តារ នឹងកសាងសេដ្ឋកិច្ច កសាងប្រទេសជាថ្មី ហើយនឹងពង្រឹងរដ្ឋអំណាចរបស់ខ្លួន ជាលំដាប់ ។ គឺក្នុងសភាពការណ៍វិវត្តល្អនេះហើយ ដែលកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ បានចាត់តាំង អង្គការរដ្ឋខ្លួន ដោយជោគជ័យ ក្នុងមហាសាមគ្គីជាតិរឹងប៉ឹង ។

តែទោះជាយ៉ាងនេះក៏ដោយ ក៏យើងខ្ញុំ ត្រូវពង្រឹង នឹងពង្រីក ស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ ជាប់ជានិច្ចតទៅទៀត ព្រោះពិសោធរាប់មិនអស់ របស់យើងខ្ញុំ បានបង្រៀនយើងខ្ញុំថា មារសត្រូវមិនបោះបង់ចោល នូវគោលបំណងបំផ្លិចបំផ្លាញ បដិវត្តរបស់យើងខ្ញុំទេ ។

×

× ×

លោកស្រីប្រធាន
ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

រដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលចាប់បដិសន្ធិក្រោយមហាជ័យជំនះ ១៧ មេសា ១៩៧៥ ប្រកាន់ដាច់ខាតនយោបាយមិនចូលបក្សសម្ព័ន្ធ ។ គោលជំហរនេះ បានលក្ខណៈជាយុទ្ធសាស្ត្រ មិនមែនជានយោបាយបត់បែន តាមកាលៈទេសៈទេ ពីព្រោះនយោបាយនេះ ជាសំណូមពរដ៏ជ្រាលជ្រៅ របស់ប្រជាជន



កម្ពុជាយើងខ្ញុំ ។ គោលជំហរនេះ យើងខ្ញុំបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន តាំងពីឆ្នាំ ១៩៥៥ ហើយក្នុងពេលប្រជាជនយើងខ្ញុំ កំពុងធ្វើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន ប្រឆាំងសង្គ្រាមឈ្លានពាន របស់ចក្រពត្តិអាមេរិក នឹងបរិវារ ដ៏សែនឃោរឃៅ ឆ្នាំ ១៩៧០ - ១៩៧៥ ក៏យើងខ្ញុំនៅតែប្រកាន់ខ្ជាប់ទៀត ។ ក្រោយបានទទួលជ័យជំនះ ក៏យើងខ្ញុំបានប្រកាន់ជាបន្តបន្ទាប់មកទៀត រហូតដល់មានកំណត់ជាលាយលក្ខអក្សរ នៅក្នុងរដ្ឋធម្មនុញ្ញយើងខ្ញុំ ។ រដ្ឋធម្មនុញ្ញយើងខ្ញុំ កំណត់ច្បាស់ថា :

« កម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្នុងមហាគ្រួសារ ប្រទេសមិនចូលបក្សសម្ព័ន្ធណាដាច់ខាត » ។

យើងខ្ញុំធ្លាប់រងគ្រោះ ដោយអំពើជ្រៀតជ្រែក អន្តរាគមន៍ នឹងឈ្លានពានរាប់សតវត្សមកហើយ ។ ក្នុងកំឡុងកាលនោះ ទឹកដីយើងខ្ញុំត្រូវបាត់បង់ នឹងត្រូវខ្ញុំគេយ៉ាងថោកទាប ។ កិត្តិយសជាតិ នឹងប្រជាជនយើងខ្ញុំ ត្រូវជាន់ឈ្លីក្នុងភក់ជ្រាំ ដ៏អសោច ។ ព្រលឹងជាតិទាំងមូល សឹងត្រូវសាបសូន្យទាំងអស់ ។ ឥឡូវ ប្រទេស នឹងប្រជាជនយើងខ្ញុំ បានរំដោះហើយ ។ តាមរយៈនេះ កិត្តិយសជាតិ នឹងព្រលឹងជាតិ បានដណ្តើមមកវិញហើយ ។ ប្រជាជនយើងខ្ញុំ បានស្មារតីស្នេហាជាតិមាតុភូមិខ្លួន យ៉ាងមុតមាំ នឹងត្រឹមត្រូវ គឺគ្មានចិត្តគំនិតលោភលន់ មើលងាយមើលថោក ចង់បានទឹកដី ឬចង់

17

ឈ្លានពានប្រទេសណាឡើយ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញយើងខ្ញុំច្បាស់ថា :

« កម្ពុជាប្រជាធិបតេយ្យ មានសុឆន្ទៈដ៏មោះមុត ចង់មានចំណងមិត្តភាពយ៉ាងជិតស្និទ្ធ ជាមួយប្រទេសទាំងអស់ ដែលមានព្រំដែនជាប់ជាមួយខ្លួន នឹងជាមួយប្រទេសជិតឆ្ងាយទាំងអស់ លើសកលលោក តាមគោលការណ៍ គោរពអធិបតេយ្យភាព បូរណភាពដែនដី ទៅវិញទៅមកដាច់ខាត ។

« កម្ពុជាប្រជាធិបតេយ្យ ប្រកាន់ខ្ជាប់នូវនយោបាយឯករាជ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធណា មិនអនុញ្ញាតឱយបរទេសណា តាំងមូលដ្ឋានសឹកនៅក្នុងប្រទេសកម្ពុជាដាច់ខាត តស៊ូដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីខាងក្រៅមកក្នុងកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា តស៊ូដាច់ខាតនឹងអំពើវិទ្ធង្សនា ឈ្លានពានគ្រប់បែបយ៉ាងពីខាងក្រៅ ... ។

« កម្ពុជាប្រជាធិបតេយ្យ មិនជ្រៀតជ្រែកដាច់ខាតកិច្ចការផ្ទៃក្នុងប្រទេសណាទាំងអស់ ... គោរពដាច់ខាតលក្ខការណ៍ ដែលប្រទេសនីមួយ ៗ មានអធិបតេយ្យភាព នឹងមានសិទ្ធិអំណាចចាត់ចែង នឹងសំរេចកិច្ចការប្រទេសខ្លួន ដោយខ្លួនឯងពេញទី គ្មានការជ្រៀតជ្រែកមកពីខាងក្រៅ » ។

ប្រទេសយើងខ្ញុំតូច មានប្រជាជនតិច ហើយនៅក្រ ។ តែប្រជាជនយើងខ្ញុំស្រឡាញ់ឯករាជ សន្តិភាព ដូចប្រជាជនឯទៀតដែរ ។ ប្រជាជនយើងខ្ញុំ មានកិត្តិយសជាតិរបស់ខ្លួន



ហើយត្រូវការពារកិត្តិយសជាតិរបស់ខ្លួនដាច់ខាត ការពារឯករាជជាតិរបស់ខ្លួនដាច់ខាត ការពារបូរណភាពដែនដីរបស់ខ្លួនដាច់ខាត ដូចប្រជាជនឯទៀតដែរ ។ ប្រជាជនយើងខ្ញុំ ត្រូវការកាន់កាប់វាសនារបស់ខ្លួន ដោយខ្លួនឯង មិនចង់ឱយបរទេសណាមកចាត់ចែងវាសនារបស់ខ្លួនដាច់ខាត ដូចប្រជាជនឯទៀតដែរ ។ ដូច្នេះ ប្រជាជនយើងខ្ញុំត្រូវការ ការពារលក្ខការណ៍ស្មើភាព គោរពឯករាជ អធិបតេយ្យភាព បូរណភាពទឹកដី ទៅវិញទៅមក គោរពផលប្រយោជន៍គ្នាទៅវិញទៅមក ដូចប្រទេសឯទៀតដែរ ។ លក្ខការណ៍នេះ ប្រទេសយើងខ្ញុំតែងតែគោរព នឹងការពារជានិច្ច ពីព្រោះជាសំណូមពររបស់ប្រជាជនកម្ពុជាយើងខ្ញុំ ។ យើងខ្ញុំពេញចិត្តពេញថ្លើម ហើយជឿជាក់ថា ប្រទេសតូច ប្រទេសមធ្យម ប្រទេសនៅក្រ ប្រទេសទន់ខ្សោយយើងទាំងអស់ នៅលើសកលលោក ត្រូវការណាស់ នូវលក្ខការណ៍នេះ ហើយកំពុងខិតខំពុះពារ ថែរក្សាការពារ នូវលក្ខការណ៍នេះ ។

ដូច្នេះហើយ បានជាកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ស្ថិតនៅក្នុងមហាគ្រួសារមិនចូលបក្សសម្ព័ន្ធនេះ ។ មហាគ្រួសារប្រទេសមិនចូលបក្សសម្ព័ន្ធ ជាមហាគ្រួសាររបស់យើងខ្ញុំ ។ យើងខ្ញុំគ្មាននៅកន្លែងណាទៀតទេ ។ យើងខ្ញុំស្រឡាញ់ពេញចិត្តមហាគ្រួសារនេះ ។ យើងខ្ញុំ ប្តេជ្ញារួបសាមគ្គី រួបសកម្មភាពក្នុងមហាគ្រួសារនេះ ការពារពង្រឹង នឹងពង្រីកលក្ខការណ៍ដ៏ពិសិដ្ឋ

របស់មហាគ្រួសារយើង ឲ្យរស់ពីចិត្តពីថ្លើម តាមលទ្ធភាពរបស់ប្រទេសយើងខ្ញុំ ដែលទើបតែចេញពីសង្គ្រាម ។

ព្រមជាមួយនេះ កម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ប្រឹងប្រែងអស់កំឡាំងកាយ កំឡាំងចិត្ត ដើម្បីសាមគ្គី និងឧបត្ថម្ភចលនាបដិវត្តប្រជាជនសកលលោក និងចលនាតស៊ូរបស់ប្រជាជនតតិយលោកជាបងប្អូន ដើម្បី ឯករាជភាព សេរីភាព ប្រជាធិបតេយ្យ មិត្តភាព និងវឌ្ឍនភាពសង្គម ។ យើងខ្ញុំចាត់ទុកការឧបត្ថម្ភគាំទ្រនេះ ជាភារកិច្ចបដិវត្តដ៏ឧត្តុង្គឧត្តម របស់យើងខ្ញុំ ។ ប្រទេសយើងខ្ញុំតូច ប្រជាជនយើងខ្ញុំនៅក្រ ហើយទើបតែចេញពីសង្គ្រាម ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏យើងខ្ញុំខិតខំរួមសាមគ្គី ជួយឧបត្ថម្ភគាំទ្រ ឲ្យអស់លទ្ធភាពរបស់ខ្លួន ពិសេសខាងស្មារតី ខាងផ្លូវចិត្ត ខាងគោលជំហរនយោបាយ ដាច់ខាតដោយឈរនៅខាងប្រជាជនតតិយលោក ជាបងប្អូន គ្រប់កាលៈទេសៈ ដាច់ខាត ប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយម និងគ្រប់អំពើឈ្លានពាន និងអំពើជ្រៀតជ្រែកពីខាងក្រៅ ។

យើងខ្ញុំ បានជំនឿជឿជាក់ថា ការលះបង់របស់ប្រជាជនយើងខ្ញុំ ក្នុងការតស៊ូប្រឆាំងនឹងសង្គ្រាមឈ្លានពាន របស់ចក្រពត្តិអាមេរិក ដើម្បីរំដោះជាតិ រំដោះប្រជាជនយើងខ្ញុំ ជាការរួមចំណែកមួយតូច ក្នុងការតស៊ូរបស់ប្រជាជនសកលលោក ប្រឆាំងចក្រពត្តិនិយម អាណានិគមនិយម និងជាការរួមចំណែកមួយតូច ក្នុងការពង្រឹងខ្លឹមសារ នៃលក្ខការណ៍មិនចូលបក្សសម្ព័ន្ធយើងដែរ ។



តទៅមុខទៀត ប្រជាជនយើងខ្ញុំ បានជំនឿជឿជាក់ថា ការដែលខ្លួនខិតខំធ្វើបដិវត្ត នៅក្នុងប្រទេសខ្លួន ឲ្យបានល្អ ខិតខំប្រយុទ្ធស្តារសេដ្ឋកិច្ច និងកសាងប្រទេសខ្លួន ឲ្យបានល្អ ដោយគោលជំហរឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន ក៏ជាការរួមចំណែកមួយតូចទៀត ដល់ចលនាតស៊ូបដិវត្ត របស់ប្រជាជនសកលលោក ដល់ចលនាតស៊ូរំដោះជាតិ របស់ប្រជាជនតតិយលោកជាបងប្អូន និងដល់ការលើកស្ទួយ នៃបុព្វហេតុ នៃមហាគ្រួសារមិនចូលបក្សសម្ព័ន្ធ របស់យើងដែរ ។ ពាក្យស្លោករបស់យើងខ្ញុំ គឺ ខំប្រឹងប្រែងធ្វើបដិវត្តខ្លួន ដោយខ្លួនឯង ឲ្យបានល្អ ទើបរួមចំណែកជាមួយបដិវត្តសកលលោក និងការតស៊ូរបស់ប្រជាជនតតិយលោកបានល្អ ។

× × ×

លោកស្រីប្រធាន
ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

តទៅនេះ យើងខ្ញុំសូមបញ្ជាក់ នូវគោលជំហររបស់យើងខ្ញុំ លើបញ្ហាជាបច្ចុប្បន្នភាពមួយចំនួន ដូចតទៅ ៖

## បញ្ហាកូរ៉េ ៖

សព្វថ្ងៃនេះ ចក្រពត្រអាមេរិកចចេសបន្តការជិះជាន់របស់វា នៅភាគខាងត្បូងកូរ៉េតទៅទៀត ដោយបន្តពង្រឹង និងពង្រីកមូលដ្ឋានសឹករបស់វា ហើយវាមានផែនការបង្កភ្លើងឈ្លានពានរបស់វា ប្រឆាំងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។ ហេតុនេះ បានជាពួកវាបានបង្កើនចំនួនកងទ័ពឈ្លានពានរបស់វា នៅកូរ៉េខាងត្បូង ហើយបានបញ្ចូលអាវុធយុទ្ធភ័ណ្ឌទំនើប ៗ ជាច្រើនទៀត រហូតដល់អាវុធបរមាណូទៅកូរ៉េខាងត្បូង ។ ចក្រពត្រអាមេរិក បានចាត់ចែងធ្វើយុទ្ធនាការ បង្កភ្លើងជាច្រើនប្រឆាំង និងគំរាមឈ្លានពាន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងដាច់ខាតនឹងនយោបាយបង្កភ្លើងឈ្លានពាន របស់ចក្រពត្រអាមេរិក លើសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។ ចក្រពត្រអាមេរិក ត្រូវតែដកទ័ពរបស់ខ្លួនទាំងអស់ រំលាយមូលដ្ឋានសឹករបស់ខ្លួនទាំងអស់ ពីកូរ៉េខាងត្បូង ត្រូវរំលាយរបស់ដែលហៅថា «អគ្គបញ្ជាការដ្ឋានអង្គការសហប្រជាជាតិ» ហើយប្តូរកិច្ចព្រមព្រៀងផ្អាកសង្គ្រាមនៅកូរ៉េ ឱ្យទៅជាកិច្ចព្រមព្រៀងសន្តិភាពវិញ ។ ចក្រពត្រអាមេរិក ត្រូវទុកឱ្យប្រជាជនកូរ៉េបង្រួបបង្រួមមាតុប្រទេសខ្លួន ដោយឯករាជម្ចាស់ការ និងសន្តិវិធី ។



យើងខ្ញុំគាំទ្រដាច់ខាត គោលការណ៍ ៣ ខ និងទិសការងារ ៥ ខ ដែលលោកប្រធានាធិបតី គីម អ៊ីល ស៊ុង បានលើកឡើង ដើម្បីដោះស្រាយបញ្ហាកូរ៉េ ។

## បញ្ហាទីម័រខាងកើត ៖

យើងខ្ញុំ សាមគ្គីដាច់ខាត និងទាំងស្រុង ជាមួយការតស៊ូដ៏យុត្តិធម៌របស់ប្រជាជន និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិប-តេយ្យទីម័រខាងកើត ក្រោមការដឹកនាំរបស់រណសិរ្សបដិវត្តដើម្បីឯករាជទីម័រខាងកើត-ហ្វ្រេទីលីន-ប្រឆាំងនឹងការឈ្លានពាន និងឧបាយកល លេបទឹកដីមកពីខាងក្រៅ ។ ទឹកដីទីម័រខាងកើត ត្រូវប្រជាជនទីម័រខាងកើត កាន់កាប់ និងធ្វើជាម្ចាស់ពេញទី ។

## បញ្ហាតំបន់អាស៊ីអគ្នេយ៍ ៖

យើងខ្ញុំមានសំណូមពរចង់ឱ្យតំបន់អាស៊ីអគ្នេយ៍ ទៅជាតំបន់ឯករាជ អព្យាក្រិត សន្តិភាពពិតប្រាកដ ។ គឺក្នុងន័យថា នៅបច្ចុប្បន្ន ក៏ដូចទៅអនាគត តំបន់អាស៊ីអគ្នេយ៍ ជាតំបន់មួយដែលប្រទេសនីមួយៗ ឯករាជពិតប្រាកដ អព្យាក្រិតពិតប្រាកដ គ្មានមូលដ្ឋានយោធាបរទេស ឬកំឡាំងយោធាបរទេស នៅលើដែនដី និងដែនសមុទ្រខ្លួន និងលើសមុទ្រជុំវិញខ្លួន បានសិទ្ធិចាត់ចែងវាសនាខ្លួនដោយខ្លួនឯងពេញទី ។ គឺជាតំបន់មួយដែលគ្មានការជ្រៀតជ្រែក និងអន្តរាគមន៍ពីបរទេស ទោះជាតាមរូបភាពណាក៏ដោយ នៅពេលបច្ចុប្បន្ន ក៏ដូចអនាគត ។ សំណូមពរ

នេះ សមស្របពេញទីនឹងខ្លឹមសារ នៃលក្ខការណ៍មិនចូលបក្សសម្ព័ន្ធរបស់យើង ។ លុះត្រាតែគ្មានមូលដ្ឋានយោធា ឬកំឡាំងយោធាបរទេស នឹងលុះត្រាតែគ្មានការជ្រៀតជ្រែក នឹងអន្តរាគមន៍ ទោះតាមរូបភាពណាក៏ដោយ ទើបប្រទេសនៅតំបន់នេះ អាចរស់នៅក្នុងឯករាជ នឹងអធិបតេយ្យភាពពិតប្រាកដ ។

## បញ្ហាប៉ាឡេស្ទីន នឹងមជ្ឈិមបូព៌ា :

កម្ពុជា ដែលធ្លាប់ឧបត្ថម្ភគាំទ្រដាច់ខាត នូវការតស៊ូដ៏យុត្តិធម៌របស់ប្រជាជនប៉ាឡេស្ទីន ប្រឆាំងស៊ីយោនិសនិយមអ៊ីស្រាអែល សូមធានាអះអាងសាជាថ្មី នូវការឧបត្ថម្ភគាំទ្ររបស់ខ្លួន ចំពោះប្រជាជនប៉ាឡេស្ទីន តទៅទៀត រហូតដល់ប្រជាជនប៉ាឡេស្ទីន សំរេចសិទ្ធិជាតិដ៏ពិសិដ្ឋរបស់ខ្លួន សិទ្ធិវិលត្រឡប់ទៅរស់នៅក្នុងមាតុភូមិខ្លួនវិញ សិទ្ធិចាត់ចែងវាសនាខ្លួន ដោយខ្លួនឯង នឹងសិទ្ធិបង្កើតរដ្ឋប៉ាឡេស្ទីន លើទឹកដីប៉ាឡេស្ទីន ដែលជាមាតុភូមិរបស់ខ្លួន ។ ប្រជាជនប៉ាឡេស្ទីន ជាវីរប្រជាជន ដែលបានតស៊ូយូរលង់មកហើយ យ៉ាងអង់អាចក្លាហាន នឹងមានបទពិសោធជាច្រើនមកហើយ ក្រោមការដឹកនាំ របស់អង្គការសេរីកាប៉ាឡេស្ទីន ។ យើងខ្ញុំ នឹងសាមគ្គី ជាមួយប្រទេសមិនចូលបក្សសម្ព័ន្ធទាំងអស់ ធ្វើយ៉ាងណា ឲយប្រជាជនប៉ាឡេស្ទីន ដណ្តើមសិទ្ធិខាងលើនេះ របស់ខ្លួនបានទាំងអស់ ។ ទន្ទឹមនឹងនេះ យើងខ្ញុំគាំទ្រដាច់ខាត ការតស៊ូរបស់ប្រទេសអារ៉ាប់ ដើម្បីដណ្តើមយកទឹកដីខ្លួន ដែលស៊ីយោនិសនិយមអ៊ីស្រាអែល រឹបយកកាន់កាប់តាំងពី ១៩៦៧ មក ។ យើងខ្ញុំជឿជាក់ថា តាមការតស៊ូដ៏ស្វិតស្វាញ នឹងដាច់ខាត របស់ប្រជាជនប៉ាឡេស្ទីន នឹងប្រជាជនអារ៉ាប់ រួមជាមួយការជួយឧបត្ថម្ភគាំទ្រ របស់ប្រជាជនសកលលោក បុព្វហេតុដ៏យុត្តិធម៌ នឹងដ៏ពិសិដ្ឋ របស់ប្រជាជនប៉ាឡេស្ទីន នឹងប្រជាជនអារ៉ាប់ទាំងអស់ មុខជាចទួលបានជ័យជំនះទាំងស្រុង ជាចីរស្សាន ។



## បញ្ហានៅអាហ្វ្រិក :

យើងខ្ញុំសំដែងការគាំទ្រជាថ្មី ចំពោះការតស៊ូរបស់ប្រជាជនស៊ីមបាប់វ៉េ ក្រោមការដឹកនាំរបស់ ក្រុមប្រឹក្សាជាតិអាហ្វ្រិក ដើម្បីឯករាជ នឹងដើម្បីចាត់ចែងវាសនាខ្លួន ដោយខ្លួនឯង ប្រឆាំងនឹងពួកពូជសាសន៍និយមស្បែកស ម៉ាន់ស្មីត ។ យើងខ្ញុំគាំទ្រការតស៊ូប្រជាជន ណាមីប៊ី ក្រោមការដឹកនាំរបស់ អង្គការប្រជាជននីរតីអាហ្វ្រិក-ស្វាប៉ូ- ដើម្បីឯករាជ ឯកភាព នឹងបូរណភាពដែនដីប្រទេសណាមីប៊ី ប្រឆាំងការជិះជាន់របស់ពួកពូជសាសន៍និយមអាហ្វ្រិកខាងត្បូង នឹងប្រឆាំងនយោបាយ បង់ទូស្តង់ របស់ពួកវា ។ យើងខ្ញុំសូមវាយដំឡៃយ៉ាងខ្ពស់ ហើយគាំទ្រការតស៊ូ ប្រកបដោយវីរភាព របស់ប្រជាជនស្បែកខ្មៅ អាសានី ដើម្បីរំដោះប្រទេសខ្លួនពីនឹមអាណានិគមនិយម ពូជសាសន៍និយម វ័រស្ទ័រ ។ យើងខ្ញុំជឿជាក់ថា ប្រជាជន ស៊ីមបាប់វ៉េ ណាមីប៊ី អាសានី នឹងដណ្តើមបានជ័យជំនះទាំងស្រុង ដាច់ខាត ។

យើងខ្ញុំគាំទ្រសេចក្ដីសំរេចចិត្ត ដ៏អង់អាចក្លាហានរបស់រដ្ឋាភិបាលប៉ូសំប៊ិច ដែលបិទព្រំដែនរបស់ខ្លួន ជាមួយរបបពូជសាសន៍និយមយ៉ាន់ស្មិត ។ យើងខ្ញុំគាំទ្រប្រទេសជាមិត្តនៅតំបន់អាហ្វ្រិកខាងត្បូងទាំងអស់ ដែលប្រឹងអស់កំឡាំងកាយកំឡាំងចិត្ត ដើម្បីឧបត្ថម្ភគាំទ្រការតស៊ូ ប្រជាជនស៊ីមបាប់វ៉េណាមីប៊ី អាសានី ។ យើងខ្ញុំគាំទ្រសេចក្ដីសំរេចចិត្តរបស់អង្គការឯកភាពអាហ្វ្រិក បង្កើនការតស៊ូ ដើម្បីរំដោះតំបន់អាហ្វ្រិកខាងត្បូង ឱយបានរហ័ស ។

យើងខ្ញុំគាំទ្រដាច់ខាត នូវឯកភាព នឹងបូរណភាពដែនដីរបស់ប្រជុំកោះកូម័រ ហើយចាត់ទុកកោះម៉ាយ៉ុត ជាចំណែកមួយនៃប្រជុំកោះកូម័រឯករាជ ។ យើងខ្ញុំទាមទារឱយបញ្ចប់អាណានិគមនិយមលើកោះម៉ាយ៉ុត ដើម្បីឱយកោះនេះ វិលចូលមកជាទឹកដី នៃប្រជុំកោះកូម័រវិញ ។ យើងខ្ញុំគាំទ្រការតស៊ូ របស់ប្រជាជនឆ្មេរសូម៉ាលី ប្រឆាំងអាណានិគមនិយមបារាំង ដើម្បីឯករាជ នឹងសេរីភាពតំបន់នេះ ។ ចំពោះបញ្ហាសាហារ៉ាខាងលិច យើងខ្ញុំឈរលើលក្ខការណ៍ ប្រជាជនមានសិទ្ធិចាត់ចែងវាសនាខ្លួនដោយខ្លួនឯង ដែលជាលក្ខការណ៍ដ៏ពិសិដ្ឋ របស់មហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ។

## បញ្ហាមួយចំនួន នៅអាមេរិកឡាទីន :

យើងខ្ញុំគាំទ្រការតស៊ូប្រជាជនព័រតូរីកូ ប្រឆាំងអាណានិគមនិយមអាមេរិក ដើម្បីឯករាជរបស់ខ្លួន ។ យើងខ្ញុំសាមគ្គី



ជាមួយការតស៊ូ របស់សាធារណរដ្ឋគុយបា ដើម្បីកំចាត់មូលដ្ឋានសឹកអាមេរិក នៅហ្គាន់តាណាម៉ូ ឱយអស់ពីទឹកដីគុយបា ។ យើងខ្ញុំគាំទ្រប្រជាជន នឹងរដ្ឋាភិបាលប៉ាណាម៉ា ក្នុងការទាមទារអធិបតេយ្យភាព លើតំបន់ព្រែកជីក ។ យើងខ្ញុំគាំទ្រសិទ្ធិរបស់ប្រជាជនបេលីស៍ ដើម្បីឯករាជ នឹងដើម្បីរក្សាបូរណភាពទឹកដីរបស់ខ្លួន ។ ព្រមជាមួយនេះ កម្ពុជាប្រជាធិបតេយ្យចាត់ទុកជាការត្រឹមត្រូវ នូវការទាមទារកាន់កាប់ កោះម៉ាល់វីនរបស់សាធារណរដ្ឋ អារសង់ទីន ។ យើងខ្ញុំគាំទ្រការតស៊ូរបស់ប្រទេសអាមេរិកឡាទីន ដើម្បីរក្សាសិទ្ធិ លើធនធានជាតិរបស់ខ្លួន នឹងដើម្បីកំចាត់សភាពរណបបរទេស នឹងការជិះជាន់បរទេស ។

## បញ្ហាមហាសមុទ្រឥណ្ឌា នឹងមហាសមុទ្រឯទៀត:

យើងខ្ញុំចង់ឱយតំបន់សមុទ្រទាំងអស់ ទាំងតំបន់មហាសមុទ្រឥណ្ឌា ទាំងតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ទាំងតំបន់មហាសមុទ្រអាត់ឡង់ទិក នឹងតំបន់សមុទ្រឯទៀត ។ ទោះធំក្ដី តូចក្ដី ទៅជាតំបន់សន្តិភាព ក្នុងន័យថា មិនឱយមានមូលដ្ឋានយោធា ឬសកម្មភាពទាំងអស់ណា ដែលនាំឱយស្ថានការណ៍តឹងតែង នឹងមានការគំរាមកំហែង ប៉ះពាល់ដល់តំបន់ទាំងនោះ ។ នេះជាសំណូមពររបស់ប្រជាជនកម្ពុជា នឹងរបស់ប្រជាជនទាំងអស់ ដែលស្នេហាសន្តិភាពពិតប្រាកដក្នុងសកលលោកដែរ ។

## បញ្ហាសេដ្ឋកិច្ច :

របបសេដ្ឋកិច្ចអន្តរជាតិបច្ចុប្បន្ន នាំឲយប្រទេសពិភពលោក ចេះតែចុះក្រទៅ ៗ ដោយការជិះជាន់ កេងប្រវ័ញ្ច ផ្សេងៗរបស់ប្រទេសអ្នកមាន ។ តាំងពីសន្និសីទកំពូលទី ៤ នៅអាល់ស៊េរី មក មហាគ្រួសារយើង បានសាមគ្គីធ្វើសកម្មភាព ដោយឯកភាព ដើម្បីបង្កបង្កើតរបបសេដ្ឋកិច្ចអន្តរជាតិថ្មី ឈរលើលក្ខការណ៍ស្មើភាព នឹងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។ ព្រមជាមួយនេះ ប្រទេសមិនចូលបក្សសម្ព័ន្ធយើង បានខំប្រឹងប្រែង ពង្រឹងនឹងពង្រីកសហប្រតិបត្តិការ រវាងគ្នា ។ ប្រទេសកំពុងអភិវឌ្ឍ បានសំរេចជោគជ័យច្រើន ក្នុងការការពារសិទ្ធិគ្រប់គ្រងធនធានជាតិ នឹងសិទ្ធិអធិបតេយ្យភាព ជាចុងទៅរបស់ខ្លួន ។ ចលនាយើងបានខបត្តម្ភគ្នាទៅវិញទៅមក ដើម្បីប្រឆាំងការរៀបសង្កត់តំរាមកំហែង ការរើសអើង នឹងអន្តរាគមន៍ពីប្រទេសអ្នកមាន ។ ពិតមែនតែយើងដណ្តើមបានជោគជ័យខ្លះ ក្នុងការតស៊ូរបស់យើង តែការតស៊ូដែលយើងត្រូវធ្វើ ដើម្បីសំរេចរបបសេដ្ឋកិច្ចអន្តរជាតិថ្មី នៅមានឆ្ងាយស្ទិតស្វាញតទៅទៀត ដោយសារប្រទេសអ្នកមាន រារាំងដំណើរយើង ដើម្បីរក្សារបបសេដ្ឋកិច្ចអន្តរជាតិចាស់ បន្តការជិះជាន់ កេងប្រវ័ញ្ចលើប្រទេសយើងតទៅទៀត ។ ដូច្នេះ យើងចាំបាច់រួបរួមសាមគ្គីតស៊ូដោយស្វិតស្វាញតទៅទៀត ដើម្បីឲយមានរបបសេដ្ឋកិច្ចអន្តរជាតិថ្មី ។ យើងខ្ញុំជឿជាក់ តាមការ-



ពិសោធមកថា តាមការខំប្រឹងប្រែងពុះពារខបសគ្គ កសាងសេដ្ឋកិច្ចរបស់យើង ដោយឯករាជ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ជាមូលដ្ឋាន ធ្វើជាកត្តាកំណត់ ព្រមជាមួយនេះ តាមការរួមសាមគ្គីជួយឧបត្ថម្ភគាំទ្រ លើកទឹកចិត្តគ្នាទៅវិញទៅមក នៃប្រទេសយើងដែលនៅក្រផង ហើយនឹងតាមការរួបសាមគ្គី តស៊ូ ដ៏ស្វិតស្វាញ នឹងដាច់ខាតរបស់ប្រទេសយើងដែលនៅក្រ ប្រឆាំងនឹងរបបសេដ្ឋកិច្ចចាស់ ជិះជាន់កេងប្រវ័ញ្ចរបស់ប្រទេសអ្នកមាន ផងនោះ យើងនឹងទទួលបានជ័យជំនះ ក្នុងការសំរេចរបបសេដ្ឋកិច្ចអន្តរជាតិថ្មី តាមគោលបំណងយើងជាប្រាកដ ។

× × ×

លោកស្រីប្រធាន
ព្រះករុណា ឯកឧត្តមប្រមុខរដ្ឋ ឯកឧត្តមប្រមុខរដ្ឋាភិបាល
ឯកឧត្តមតំណាងដ៏ឧត្តម

យើងខ្ញុំចាត់ទុកសន្និសីទកំពូលលើកទី ៥ នៃមហាគ្រួសារយើង នៅកូឡុំបូ នេះ ជាដំណាក់កាលមួយសំខាន់ ក្នុងការពង្រឹងនឹងពង្រីកតួនាទី នឹងសកម្មភាពរបស់ចលនាយើង ។ ដោយមានជំនឿជឿជាក់ លើចលនាយើងនេះ យើងខ្ញុំសង្ឃឹមថា ចេញពីសន្និសីទកំពូលលើកទី ៥ នេះទៅ ចលនាយើងនឹងឯកភាពគ្នា

23

ហើយសាបគ្គីគ្នា រឹតតែខ្លាំងឡើង ដើម្បីធ្វើឲយខ្ទឹមសារ នៃលក្ខការណ៍ដ៏ពិសិដ្ឋ នៃមហាគ្រួសារមិនចូលបក្សសម្ព័ន្ធយើង ពង្រឹងនឹងពង្រីក នឹងមានឥទ្ធិពលកាន់តែខ្លាំងក្លា ហើយមហាគ្រួសារយើង នឹងដណ្ដើមជ័យជំនះត្រចះត្រចង់ថែមទៀត ។

សូមអរគុណ ។

( ថ្ងៃ ១៧ សីហា ១៩៧៦ )

×

× ×